**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...១៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលសមាសភាពនៃលេខាធិការដ្ឋានឥណទានកម្មវិធី របស់ធនាគារអភិវឌ្ឍន៍អាស៊ី លេខ ១៤៤៥-CAM(SF)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ខែវិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ
- បានឃើញព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់សហលក្ខន្តិកៈ មន្ត្រីរាជការ ស៊ីវិល
- បានឃើញអនុក្រឹត្យ លេខ ៩៩ អនុក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទីភារកិច្ច និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ
- បានឃើញកិច្ចព្រមព្រៀងឥណទាន លេខ ១៤៤៥-CAM (SF) ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៦ រវាងព្រះរាជាណាចក្រកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីឥណទានកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម
- បានឃើញឯកសារជំនួយស្មារតីរបស់ ADB ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០០០
- បានឃើញសេចក្តីសំរេច ស្តីពីការបង្កើតលេខាធិការដ្ឋានឥណទានកម្មវិធី របស់ធនាគារអភិវឌ្ឍន៍អាស៊ី លេខ ១៤៤៥ -CAM (SF) និង ក្រុមការងារសំរាប់អនុវត្តន៍កម្មវិធីឥណទានរបស់ធនាគារ អភិវឌ្ឍន៍អាស៊ី

## សំរេច

**មាត្រា ១** : ត្រូវបានកែសំរួលសមាសភាពរបស់លេខាធិការដ្ឋានឥណទានកម្មវិធី សំរាប់អនុវត្តកម្មវិធីកែទំរង់វិស័យកសិកម្មក្នុងក្របខ័ណ្ឌឥណទាន ធនាគារអភិវឌ្ឍន៍អាស៊ី ( Asian Development Bank ) លេខ ១៤៤៥ - CAM (SF) ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ (CARD) ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **ច័ន្ទ សុខអ៊ីម** | រដ្ឋលេខាធិការ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ប្រធាន |
| ២- | ឯកឧត្តម **នូច កានុន** | អគ្គលេខាធិការ CARD | អនុប្រធានទី១ និងជាអ្នកសំរបសំរួលតំណាងជាមួយក្រសួងពាក់ព័ន្ធ |
| ៣- | លោក **សាន វណ្ណនី** | អគ្គនាយករង<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | អនុប្រធានទី ២ |

### ក. ផ្នែកគណនេយ្យ-ហិរញ្ញវត្ថុ

| | | | |
|---|---|---|---|
| ១- | លោក ញឹម ច័ន្ទទេវី | ប្រធាននាយកដ្ឋានគណនេយ្យ និង ហិរញ្ញវត្ថុ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ទទួលបន្ទុកប្រធានផ្នែកគណនេយ្យ |
| ២- | លោក ស៊ៀ ធីរៈ | ប្រធានផ្នែកកសិកម្មនៃ CARD | ទទួលបន្ទុកអនុប្រធានផ្នែកគណនេយ្យ |
| ៣- | លោក ស្រី នុឌ្ឍី | ប្រធានការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ទទួលបន្ទុកអនុប្រធានផ្នែកគណនេយ្យ |
| ៤- | លោក **ខាម ឈាងលីម** | មន្ត្រីរាជការនាយកដ្ឋានផែនការស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ | ជំនួយការគណនេយ្យ |

### ខ. ផ្នែកលទ្ធកម្ម

| | | | |
|---|---|---|---|
| ១- | លោក គុំ រ៉ា | អនុប្រធាននាយកដ្ឋានធីតិកម្មកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ទទួលបន្ទុកប្រធានផ្នែកលទ្ធកម្ម |

| | | | |
|---|---|---|---|
| ២- | លោក **ស៊ុន សុខហេង** | មន្ត្រីរាជការ នាយកដ្ឋានគ្រឿងយន្តកសិកម្ម | មន្ត្រីលទ្ធកម្ម |
| ៣- | លោក **ណារិ លីម៉ា** | មន្ត្រីរាជការ នៃអគារធិការដ្ឋាន | ជំនួយការលទ្ធកម្ម |

**គ. ផ្នែករដ្ឋបាល**

| | | | |
|---|---|---|---|
| ១- | លោក **ចន្ទ ប៊ុណ្ណារិកា** | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី | ទទួលបន្ទុកប្រធានផ្នែករដ្ឋបាល |
| ២- | លោក **គង់ ប៊ុនណា** | មន្ត្រីរាជការ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល | ជំនួយការរដ្ឋបាល |
| ៣- | លោកស្រី **អ៊ុំ វណ្ណារ៉ា** | មន្ត្រីរាជការ នៃនាយកដ្ឋានផែនការ ស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ | ជំនួយការរដ្ឋបាល |
| ៤- | លោកស្រី **ឆាយ ណុច** | មន្ត្រីរាជការ នាយកដ្ឋានបុគ្គលិក និង ធនធានមនុស្ស | ជំនួយការរដ្ឋបាល |
| ៥- | លោក **ជា ចំរើន** | កងការពារ នាយកដ្ឋានកិច្ចការរដ្ឋបាល | អ្នកចែកចាយលិខិតស្នាម |
| ៦- | លោក **ម៉ែន សារ៉េន** | មន្ត្រីរាជការ នាយកដ្ឋានបុគ្គលិក និង ធនធានមនុស្ស | សន្តិសុខ |
| ៧- | កញ្ញា ទុធ សុធា | | អ្នកបំរើការិយាល័យ |

**ឃ. ផ្នែកតាមដាន និង វាយតម្លៃ**

| | | | |
|---|---|---|---|
| ១- | លោក **ចាយ បូរិន** | ប្រធានផ្នែកផ្គត់ផ្គង់ និង ហិរញ្ញវត្ថុ នៃ CARD | ទទួលបន្ទុកប្រធានផ្នែកតាមដាន និង វាយតម្លៃ |
| ២- | លោក **ហុង លាងហេង** | អនុប្រធានក្លាប់រួមផ្នែកធនធានទឹក នៃ CARD | ទទួលបន្ទុកអនុប្រធានផ្នែកតាមដាន និង វាយតម្លៃ |

| | | |
|---|---|---|
| ៣- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | ០១ រូប | សមាជិក |
| ៤- តំណាងក្រសួងធនធានទឹក និង ឧតុនិយម | ០១ រូប | សមាជិក |
| ៥- តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ | ០១ រូប | សមាជិក |

**មាត្រា ២** : លេខាធិការដ្ឋានឥណទានកម្មវិធីមានភារៈកិច្ច ដូចខាងក្រោម:

- ដឹកនាំ និង សំរបសំរួលការអនុវត្តន៍កម្មវិធី លើវិធានការចាំបាច់សំរាប់អនុវត្តកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម តាមខ្លឹមសារនៃកិច្ចព្រមព្រៀងឥណទាន លេខ ១៤៤៥-CAM(SF) ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៦ ។

- ទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ លើការអនុវត្តន៍ឥណទានកម្មវិធី ។
- សម្របសម្រួល និង រៀបចំនូវរាល់ផែនការការងារ និង សំណើសុំថវិកាបស់ក្រុមការងារ ដើម្បីផ្ញើជូនក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សុំការយល់ព្រម ។
- ដំណើរការលទ្ធកម្មជាលក្ខណៈជាតិ និង អន្តរជាតិ រួមមាន : សំណង់ ទំនិញ និង សេវាកម្មដោយត្រូវអនុវត្តឱ្យបាន ត្រឹមត្រូវតាមនីតិវិធី និង គោលការណ៍កំណត់ដោយធនាគារអភិវឌ្ឍន៍អាស៊ី និង អនុស្សារណៈរវាងក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។
- ធ្វើបញ្ជីការគណនេយ្យប្រចាំខែ និង ប្រចាំឆ្នាំ ។
- ចុះហត្ថលេខាលើរាល់ឯកសារការងារប្រចាំថ្ងៃ របស់លេខាធិការដ្ឋាន ។
- ពិនិត្យ និង សំរេច លើការបំពាក់បំប៉ន និង ទស្សនៈកិច្ចក្រៅប្រទេស ។
- ចាត់ចែងប្រគល់ថវិកាទៅជូនក្រុមការងារអនុវត្តឥណទានកម្មវិធី ។
- ចាត់ចែងណែនាំ តាមដាន និង វាយតម្លៃ លើការអនុវត្តន៍គំរោងទាំងមូល ។
- ធ្វើការទាក់ទងផ្ទាល់ជាមួយក្រសួងស្ថាប័ន អង្គភាពពាក់ពន្ធ័ក្នុងកិច្ចដំណើរការអនុវត្តន៍កម្មវិធីឥណទាន ។
- រៀបចំរបាយការណ៍រីកចំរើនប្រចាំឆមាស និង ប្រចាំឆ្នាំ ស្តីអំពីការអនុវត្តន៍ឥណទានកម្មវិធី ផ្ញើជូន ADB និង ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** លេខាធិការដ្ឋានឥណទានកម្មវិធី សំរាប់អនុវត្តកម្មវិធីកែទំរង់វិស័យកសិកម្ម ក្នុងក្របខ័ណ្ឌឥណទានធនាគារអភិវឌ្ឍន៍អាស៊ី មានការិយាល័យប្រចាំការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងប្រើត្រារបស់ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យ កសិកម្ម និង ជនបទ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឯកឧត្តមអនុប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងសាមីជន ដូចមានរាយនាម ក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់
- ក្រសួងធនធានទឹក និង ឧតុនិយម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ